00712676

E62/3/9

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 07 / 07 / 2011
ម៉ោង (Time/Heure): 13:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

**សាធារណៈ** / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី សុំដាក់ជាសាធារណៈ នូវរបាយការណ៍ស្តីពីការថែទាំសុខភាពមនុស្សចាស់របស់សាស្ត្រាចារ្យ A. JOHN CAMPBELL**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងដាក់ជាសាធារណៈ នូវរបាយការណ៍ស្តីពីការថែទាំសុខភាពមនុស្សចាស់របស់សាស្ត្រាចារ្យ A. Jonh Campbell ទាក់ទងនឹងលោក អៀង សារី ("របាយការណ៍ស្តីពីការថែទាំសុខភាពមនុស្សចាស់")[1]។ សំណើនេះ ចាំបាច់ដើម្បីជាប្រយោជន៍នៃតម្លាភាព។ លិខិតលះបង់សិទ្ធិរក្សាភាពសម្ងាត់ និងការអនុញ្ញាតឱ្យដាក់របាយការណ៍នេះជាសាធារណៈ ដែលមានហត្ថលេខាលោក អៀង សារី ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធជាមួយសំណើនេះ។

១. កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងឱ្យសាស្ត្រាចារ្យ A. Jonh Campbell ផ្តល់ការវាយតម្លៃលើភាពសម្បទារបស់លោក អៀង សារី ដើម្បីចូលរួមសវនាការ សមត្ថភាពរបស់គាត់ក្នុងការអង្គុយរយៈពេលយូរក្នុងអំឡុងពេលជំនុំជម្រះ និងការវាយតម្លៃលើសុខភាពផ្លូវកាយរបស់គាត់[2]។

២. កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ សាស្ត្រាចារ្យ A. Jonh Campbell បានដាក់របាយការណ៍ស្តីពីការថែទាំសុខភាពមនុស្សចាស់ទៅអង្គជំនុំជម្រះសាលាដំបូង ដែលក្រោយមកទៀតរបាយការណ៍នេះបានបញ្ជូនបន្តមកឱ្យមេធាវីការពារក្តីដោយសម្ងាត់បំផុត។

៣. កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ នៅក្នុងសវនាការបឋម លោកចៅក្រម និល ណុន បានគូសបញ្ជាក់ថា របាយការណ៍ស្តីពីការថែទាំសុខភាពមនុស្សចាស់នេះនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងដោយសម្ងាត់នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១១[3]។

៤. សវនាការបឋមលើសំណុំរឿង០០២ បានចាប់ផ្តើមកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ហើយបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១។ ក្នុងអំឡុងសវនាការនេះ លោក អៀង សារី តែងតែចាកចេញពីបន្ទប់សវនាការដោយសារតែបញ្ហាសុខភាពរបស់គាត់។ លោក អៀង សារី បន្តចូលរួមតាមដានដំណើរការនីតិវិធីក្នុងបន្ទប់រង់ចាំនៅក្រោមសាលសវនាការ។

៥. លោក អៀង សារី មានចេតនាបង្ហាញវត្តមានក្នុងបន្ទប់សវនាការដើម្បីចូលរួមដំណើរការជំនុំជម្រះ

---

[1] របាយការណ៍ដែលបានរៀបចំជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់ អជសង, ឯកសារ E62/3, របាយការណ៍ស្តីពីការថែទាំសុខភាពមនុស្សចាស់- លោក អៀង សារី, ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១, ឯកសារ E62/3/5, (សម្ងាត់បំផុត)។

[2] ដីកាចាត់តាំងអ្នកជំនាញ, ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១, ឯកសារ E62/3, កថាខណ្ឌទី២ (សម្ងាត់)។

[3] ពង្រាងប្រតិចារិកអំពីសវនាការបឋមក្នុងថ្ងៃដំបូង, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១, ទំព័រទី៣២។

ក្នុងកម្រិតមួយដែលសុខភាពរាងកាយរបស់គាត់អាចធ្វើទៅបាន។ ដើម្បីជាប្រយោជន៍នៃតម្លាភាពដល់ដំណើរការនីតិវិធី និងដើម្បីជម្រះមន្ទិលដែលដើមបណ្តឹងរដ្ឋប្បវេណី ឬសាធារណៈជនទូទៅមានជាយូរមកហើយទាក់ទងនឹងបញ្ហាថាតើថាហេតុអ្វីបានជាលោក អៀង សារី បានស្នើសុំទៅតាមដានដំណើរការជំនុំជម្រះក្នុងបន្ទប់រង់ចាំ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសជាសាធារណៈនូវរបាយការណ៍ស្តីពីការថែទាំសុខភាព លោក អៀង សារី ។

អាស្រ័យលើមូលហេតុដូចដែលបានលើកឡើងពីខាងលើ មេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់ជាសាធារណៈនូវរបាយការណ៍ស្តីពីការថែទាំសុខភាពលោក អៀង សារី ជាសាធារណៈ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**